# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## សុន្ទរកថា
## របស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់
## តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងពិធីផ្ទេរតំណែងប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍

**រាជធានីភ្នំពេញ,ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០១៣**

- *ឯកឧត្តម **ឈុត សុខុម** ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍នៃរាជរដ្ឋាភិបាលនីតិកាលទី៤*
- *ឯកឧត្តម **អៀង ម៉ូលី** ទេសរដ្ឋមន្ត្រី និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ នៃរាជរដ្ឋាភិបាល នីតិកាលទី ៥*
- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍*
- *ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ !*

១. ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេកប្បការ និង កិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយបានទទួលនូវបុព្វសិទ្ធិដ៏ថ្លៃថ្លា ធ្វើជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចូលរួមជាអធិបតីក្នុងពិធីផ្ទេរតំណែងប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍នៃរាជរដ្ឋាភិបាលនីតិកាលទី៥។ ជាបឋម ក្នុងនាមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសំដែង នូវការអបអរសាទរយ៉ាងក្លៀវក្លា និងពរសព្ទសាធុការយ៉ាងកក់ក្តៅបំផុតជូនចំពោះឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង ម៉ូលី** ក្នុងការចូលកាន់តំណែងប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ នៃរាជរដ្ឋាភិបាលនីតិកាលទី៥ នេះ ។ ជាមួយនេះ

ខ្ញុំក៏សូមសំដែងនូវការកោតសរសើរ ដ៏ស្មោះជូនចំពោះឯកឧត្តម **នុត សុខុម** ដែលកន្លងមក បានខិតខំប្រឹងប្រែងយកអស់កំលាំងកាយ ប្រាជ្ញា និង ចិត្ត និងការប្តេជ្ញាខ្ពស់ក្នុងការដឹកនាំអាជ្ញាធរជាតិ ប្រយុទ្ធនឹងជម្ងឺអេដស៍ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និង ទទួលបាននូវជោគជ័យគួរជាទីមោទនៈ ។

២. រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ដែលបានប្រសូតឡើងស្របតាមឆន្ទៈរបស់ប្រជាជនកម្ពុជា តាមរយៈការបោះឆ្នោតដែលមានលក្ខណៈសេរី យុត្តិធម៌ ត្រឹមត្រូវ និងមានតម្លាភាព បានចាប់ផ្តើមការងារ ដោយបានបើកកិច្ចប្រជុំពេញអង្គលើកទី១ របស់ខ្លួន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ។

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !*

៣. រាជរដ្ឋាភិបាល នីតិកាលទី៤ នៃរដ្ឋសភា ដែលទើបបានបញ្ចប់អាណត្តិរបស់ខ្លួន កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ កន្លងទៅនេះ បានបន្សល់ទុកនូវស្នាដៃជាប្រវត្តិសាស្ត្រ និង អមតៈ ជាច្រើនរាប់មិនអស់ ដែលជាផ្លែផ្កានៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាផ្ទាល់ ក្រោមបរិការណ៍សន្តិភាព ឯកភាពទឹកដី និងស្ថេរភាពនយោបាយនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ស្ថិរភាពហិរញ្ញវត្ថុ ដែលបានប្រសូតចេញពីនយោបាយ **ឈ្នះ-ឈ្នះ** របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ។ សមិទ្ធផលទាំងនោះពុំអាចកាត់ផ្តាច់ចេញបានពីការចូលរួមចំណែករបស់សកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ ដែលធានានូវចីរភាពនៃធនធានមនុស្ស ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្រោមការគ្រប់គ្រង និង អនុវត្តរបស់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ជាពិសេស ក្រោមការដឹកនាំរបស់ឯកឧត្តម **នុត សុខុម** ក្នុងឋានៈជាប្រធានអាជ្ញាធរនេះ កន្លងមក។

៤. តាមរយៈរបាយការណ៍ស្តីពីសមិទ្ធផលការងាររយៈពេល៥ឆ្នាំដែលបានថ្លែងអម្បាញ់មិញ ដោយឯកឧត្តម **នុត សុខុម** ខ្ញុំសូមសំដែងនូវមូលវិចារណ៍ដ៏ថ្លៃថ្លាចំពោះការខិតខំរបស់យើងទាំងអស់គ្នា ដែលបានប្រឹងប្រែងយកអស់លទ្ធភាពក្នុងការធ្វើឱ្យមានចីរភាព នៃអន្តរាគមន៍ប្រយុទ្ធនឹងជម្ងឺអេដស៍ ដែលជាលទ្ធផល គឺអត្រារាលដាលមេរោគអេដស៍មាននិន្នាការធ្លាក់ចុះជាលំដាប់ ស្របជាមួយនឹងអត្រាប្រើប្រាស់ស្រោមអនាម័យដែលចេះតែកើនឡើង ការថែទាំ ការព្យាបាល និង ការគាំទ្រសង្គម កាន់តែមានគុណភាពខ្ពស់ និង ជាពិសេស ការរើសអើង និង មាក់ងាយ

ខ្ញុំក៏សូមសំដែងនូវការកោតសរសើរ ដ៏ស្មោះជូនចំពោះឯកឧត្តម **នុត សុខុម** ដែលកន្លងមក បានខិតខំប្រឹងប្រែងយកអស់កំលាំងកាយ ប្រាជ្ញា និង ចិត្ត និងការប្តេជ្ញាខ្ពស់ក្នុងការដឹកនាំអាជ្ញាធរជាតិ ប្រយុទ្ធនឹងជម្ងឺអេដស៍ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និង ទទួលបាននូវជោគជ័យគួរជាទីមោទនៈ ។

២. រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ដែលបានប្រសូតឡើងស្របតាមឆន្ទៈរបស់ប្រជាជនកម្ពុជា តាមរយៈការបោះឆ្នោតដែលមានលក្ខណៈសេរី យុត្តិធម៌ ត្រឹមត្រូវ និងមានតម្លាភាព បានចាប់ផ្តើមការងារ ដោយបានបើកកិច្ចប្រជុំពេញអង្គលើកទី១ របស់ខ្លួន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ។

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !*

៣. រាជរដ្ឋាភិបាល នីតិកាលទី៤ នៃរដ្ឋសភា ដែលទើបបានបញ្ចប់អាណត្តិរបស់ខ្លួន កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ កន្លងទៅនេះ បានបន្សល់ទុកនូវស្នាដៃជាប្រវត្តិសាស្ត្រ និង អមតៈ ជាច្រើនរាប់មិនអស់ ដែលជាផ្លែផ្កានៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ** របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាផ្ទាល់ ក្រោមបរិការណ៍សន្តិភាព ឯកភាពទឹកដី និង ស្ថេរភាពនយោបាយនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ស្ថិរភាពហិរញ្ញវត្ថុ ដែលបានប្រសូតចេញពីនយោបាយ **ឈ្នះ-ឈ្នះ** របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ។ សមិទ្ធផលទាំងនោះពុំអាចកាត់ផ្តាច់ចេញបានពីការចូលរួមចំណែករបស់សកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ ដែលធានានូវចីរភាពនៃធនធានមនុស្ស ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ក្រោមការគ្រប់គ្រង និង អនុវត្តរបស់ថ្នាក់ដឹកនាំ និង មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ជាពិសេស ក្រោមការដឹកនាំរបស់ឯកឧត្តម **នុត សុខុម** ក្នុងឋានៈជាប្រធានអាជ្ញាធរនេះ កន្លងមក។

៤. តាមរយៈរបាយការណ៍ស្តីពីសមិទ្ធផលការងាររយៈពេល៥ឆ្នាំដែលបានថ្លែងអម្បាញ់មិញ ដោយឯកឧត្តម **នុត សុខុម** ខ្ញុំសូមសំដែងនូវមូលវិចារណ៍ដ៏ថ្លៃថ្លាចំពោះការខិតខំរបស់យើងទាំងអស់គ្នា ដែលបានប្រឹងប្រែងយកអស់លទ្ធភាពក្នុងការធ្វើឱ្យមានចីរភាព នៃអន្តរាគមន៍ប្រយុទ្ធនឹងជម្ងឺអេដស៍ ដែលជាលទ្ធផល គឺអត្រារាលដាលមេរោគអេដស៍មាននិន្នាការធ្លាក់ចុះជាលំដាប់ ស្របជាមួយនឹងអត្រាប្រើប្រាស់ស្រោមអនាម័យដែលចេះតែកើនឡើង ការថែទាំ ការព្យាបាល និង ការគាំទ្រសង្គម កាន់តែមានគុណភាពខ្ពស់ និង ជាពិសេស ការរើសអើង និង មាក់ងាយ

បានកាត់បន្ថយជាបន្តបន្ទាប់ប្រកបដោយភាពជឿជាក់ថានឹងឈានទៅលុបបំបាត់ទាំងស្រុងនាឆ្នាំ ២០២០ ខាងមុខនេះ។

៥. ជាការពិត សមិទ្ធផល និង ជោគជ័យដ៏ធំធេងទាំងនេះ ប្រសិនបើពុំមានការចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី និង ការគាំទ្រពីដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល អ្នកផ្ទុកមេរោគអេដស៍ និង ផ្នែកឯកជនទេនោះ យើងពិតជាពុំអាចទទួលបាននូវលទ្ធផលដ៏ត្រចះត្រចង់បែបនេះឡើយ ជាពិសេសបំផុត ពីសំណាក់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា និង ជាមគ្គុទ្ទេសក៍ឆ្នើមប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ក្នុងការប្រយុទ្ធនឹងជម្ងឺអេដស៍ ដែលបានខិតខំយ៉ាងសកម្ម មិនចេះនឿយហត់ក្នុងការជួយជនរងគ្រោះ ដោយសារមេរោគអេដស៍/ជម្ងឺអេដស៍ ហើយត្រូវបានទទួលស្គាល់ថាជា «**ឥស្សរជនឆ្នើមថ្នាក់ជាតិ នៃវេទិកាភាពជាអ្នកដឹកនាំប្រចាំតំបន់អាស៊ី- ប៉ាស៊ីហ្វិក**» ។

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !*

៦. ក្នុងឱកាសប្រារព្ធពិធីផ្ទេរតំណែងនាពេលនេះ ខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួនជូនដល់ថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៃរាជរដ្ឋាភិបាលនីតិកាលទី៥ និង ជនរួមជាតិកម្ពុជាទាំងអស់ ដូចខាងក្រោម:

១) ទោះបីជាយើងទទួលបានជោគជ័យជាបន្តបន្ទាប់លើការទប់ស្កាត់ការរាលដាលមេរោគអេដស៍ដ៏គួរជាទីមោទនៈហើយក៏ដោយ ក៏យើងត្រូវតែខិតខំប្រឹងប្រែងឱ្យបានខ្លាំងក្លាបន្តទៀត ដើម្បីកាត់បន្ថយអត្រាឆ្លងមេរោគអេដស៍ឱ្យបាន ៥០% បន្ថែមទៀត ក្នុងចំណោមក្រុមដែលប្រឈមមុខខ្ពស់ ដូចជាក្រុមបុគ្គលិកគ្រឹះស្ថានកំសាន្តសប្បាយ ក្រុមបុរសស្រឡាញ់បុរស ក្រុមយុវ័យ និង ឈានទៅលុបបំបាត់ទាំងស្រុងនូវការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅឆ្នាំ ២០១៥។

២) ថ្នាក់ដឹកនាំស្ថាប័ន នៅគ្រប់លំដាប់ថ្នាក់ទាំងអស់ត្រូវយកបញ្ហាអេដស៍ជាអាទិភាពក្នុងការបញ្រ្ជាប និង បញ្ចូលទៅគ្រប់សេវាទាំងអស់នៅក្នុងស្ថាប័ន និង សហគមន៍របស់ខ្លួន ដើម្បីធានាថាមន្ត្រី បុគ្គលិក ប្រជាជនរបស់ខ្លួនមានចំណេះដឹងត្រឹមត្រូវអំពីមេរោគអេដស៍ និង ជម្ងឺអេដស៍ និងមានមធ្យោបាយគ្រប់គ្រាន់ក្នុងការបង្ការខ្លួនពីការចម្លងមេរោគអេដស៍។

៣) បន្តការលើកកម្ពស់សមត្ថភាព ក្នុងភាពជាអ្នកដឹកនាំល្អ ក្នុងការប្រយុទ្ធនឹងជម្ងឺអេដស៍ទៅគ្រប់លំដាប់ថ្នាក់ទាំងអស់។

៤)  ចំណេះដឹងព័ត៌មានស្តីពីមេរោគអេដស៍ និង ជម្ងឺអេដស៍ត្រូវបន្តផ្សព្វផ្សាយឱ្យបានជាប្រចាំនិងកាន់តែទូលំទូលាយ ធានាដល់ការគ្របដណ្តប់ឱ្យបានទូទាំងប្រទេសជាពិសេសនៅតាមតំបន់ដាច់ស្រយាល។

៥)  ស្រោមអនាម័យគឺនៅតែជាមធ្យោបាយដ៏មានប្រសិទ្ធភាព ក្នុងការបង្ការការចម្លងមេរោគអេដស៍នៅកម្ពុជា ។ ហេតុដូចនេះ យើងត្រូវធ្វើយ៉ាងណាឱ្យមានស្រោមអនាម័យ នៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាដែលត្រូវការប្រើប្រាស់ប្រកបដោយគុណភាពខ្ពស់និងតម្លៃសមរម្យបំផុត ជាពិសេសត្រូវតែមានការប្តេជ្ញាចិត្តយ៉ាងមោះមុតក្នុងការអនុវត្តគោលនយោបាយប្រើប្រាស់ស្រោមអនាម័យ ១០០% នៅតាមគ្រឹះស្ថានកំសាន្តសប្បាយទាំងអស់ឱ្យប្រកបដោយប្រសិទ្ធភាពខ្ពស់។

៦)  បន្តការលើកកម្ពស់យន្តការយេនឌ័រ និងជម្ងឺអេដស៍ តាមរយៈការលើកកម្ពស់សិទ្ធិអំណាច និងការផ្តល់ឱកាសដល់ស្ត្រី និងកុមារីក្នុងការចូលរួមទប់ស្កាត់ការរាលដាលមេរោគអេដស៍ ជាពិសេសនៅក្នុងរង្វង់គ្រួសារ និង សង្គមទាំងមូល។

៧)  កាត់បន្ថយជាបន្ថែមទៀត ដើម្បីឈានទៅរកការលុបបំបាត់ទាំងស្រុង នូវការរើសអើង និងមាក់ងាយដល់អ្នកផ្ទុកមេរោគអេដស៍ និងអ្នកជម្ងឺអេដស៍ តាមគ្រប់រូបភាពទាំងអស់ ជាពិសេស ពង្រឹងនូវការអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យ និង បង្ការការរីករាលដាលមេរោគអេដស៍ នៅកម្ពុជា។

៨)  កន្លងមកមានរបាយការណ៍មួយចំនួន បង្ហាញថាមានគ្រឹះស្ថានមិនមែនរដ្ឋាភិបាល និងឯកជនមួយចំនួន បានប្រើប្រាស់ការធ្វើតេស្តឈាមរកមេរោគអេដស៍ជាលក្ខខណ្ឌ ក្នុងការទទួលការងារនិងសេវារបស់ខ្លួន ឬការធ្វើតេស្តដោយគ្មានការផ្តល់ប្រឹក្សាត្រឹមត្រូវដែលខ្ញុំសូមសង្កត់ ធ្ងន់ថាការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយបង្ខំ ឬ ដោយតម្រូវ ត្រូវហាមឃាត់ជាដាច់ខាត ព្រោះវាជាអំពើខុសនឹងច្បាប់រដ្ឋ។

៩)  រាល់ការងារប្រយុទ្ធនឹងជម្ងឺអេដស៍ទាំងអស់ត្រូវបន្តឆ្លើយតបឱ្យបានទូលំទូលាយ និង ពហុវិស័យដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស សមធម៌យេនឌ័រ និងគ្មានការរើសអើង។

១០)  សូមឱ្យអង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជម្ងឺអេដស៍ទាំងអស់បន្តចូលរួមឱ្យបានខ្លាំងក្លាថែមទៀត តាមគ្រប់រូបភាព ទាំងកម្លាំងកាយ ប្រាជ្ញាស្មារតី និងថវិកា ដើម្បីពង្រីកអន្តរាគមន៍ ប្រកបដោយប្រសិទ្ធភាពឱ្យបានកាន់តែទូលំទូលាយថែមទៀតឈានទៅសម្រេចបាននូវអត្រាគ្របដណ្តប់លើគ្រប់ភូមិសាស្ត្រ គ្រប់ក្រុមគោលដៅ និងគ្រប់សេវាផងដែរ។

១១) អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវបន្តនូវបេសកកម្មដ៏ថ្លៃថ្លានេះ ក្នុងនាមជាស្ថាប័នដឹកនាំគ្រប់គ្រង សម្របសម្រួលជាតិជំនួសឱ្យរាជរដ្ឋាភិបាលក្នុងការតាមដាននូវការរាលដាលមេរោគអេដស៍ និង ការឆ្លើយតបទៅនឹងជំងឺអេដស៍តាមរយៈគោលការណ៍ភាពជាម្ចាស់ ភាពសមស្របទៅតាមគោលនយោបាយ និង យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និង ធានាសុខដុមនីយកម្មក្នុងចំណោមដៃគូអភិវឌ្ឍន៍ទាំងអស់ជាពិសេសត្រូវដើរតួឱ្យបានខ្លាំងក្លាក្នុងការដឹកនាំ គ្រប់គ្រង និងសម្របសម្រួលថវិកាមូលនិធិសកលឱ្យបានចំគោលដៅ និង អាទិភាពដូចដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និង ពហុវិស័យឆ្លើយតបទៅនឹងការរាលដាល មេរោគអេដស៍ និង ជំងឺអេដស៍លើកទី៣ ឆ្នាំ២០១១-២០១៥។ លើសពីនេះទៅទៀត ត្រូវបន្តតាមដានឱ្យបានខ្ជាប់ខ្ជួននូវវឌ្ឍនភាព និងប្រសិទ្ធិភាពនៃការវាស់វែងសូចនាកររួមគ្នារវាងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងដៃគូអភិវឌ្ឍន៍តាមរយៈការរៀបចំរបាយការណ៍ឱ្យបានទៀងទាត់ជូនរាជរដ្ឋាភិបាល។

១២) ដើម្បីធានាបាននូវប្រសិទ្ធភាព ក្នុងការឈានទៅសម្រេចបាននូវគោលដៅសូន្យបី គឺ **(១) គ្មានការចម្លងមេរោគអេដស៍ (២) គ្មានការស្លាប់ដោយសារជម្ងឺអេដស៍ និង (៣) គ្មានការរើសអើងនិងមាក់ងាយទៅលើអ្នកផ្ទុកមេរោគអេដស៍ និងជម្ងឺអេដស៍** នាឆ្នាំ២០១៥ និង ២០២០ ខាងមុខ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ត្រូវពិនិត្យឡើងវិញនូវយុទ្ធសាស្ត្រ គោលនយោបាយវិធីសាស្ត្រ ។ល។ ដែលសមស្របទៅ នឹងស្ថានភាពជាក់ស្តែងរបស់ប្រទេសកម្ពុជា និង ជាពិសេស ត្រូវធ្វើការបែងចែកនូវតួនាទី និង ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័ន នីមួយៗ ដែលជាសមាជិករបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

***ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !***

៧. ក្នុងនាម សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមប្រកាសជាឱឡារិកថា រាជរដ្ឋាភិបាលកម្ពុជានៅតែចាត់ទុកបញ្ហាអេដស៍ គឺជាបញ្ហាអាទិភាពខ្ពស់ តាមរយៈការបញ្ចូលទៅក្នុងគម្រោងអភិវឌ្ឍន៍អាទិភាពជាតិឆ្នាំ ២០១៤-២០១៦ រួចជាស្រេច និងបន្តជួយគាំទ្រតាមគ្រប់រូបភាពជាគោលនយោបាយ ជាយុទ្ធសាស្ត្រ ដើម្បីដឹកនាំឱ្យមានបរិយាកាសវិជ្ជមាន ដល់ប្រតិបត្តិករ និង សកម្មជនប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ជាពិសេស គឺការបន្តបង្កើនថវិកាជាតិ ទៅតាមលទ្ធភាពដែលរាជរដ្ឋាភិបាលអាចធ្វើទៅបាន ហើយអ្វីដែលរាជរដ្ឋាភិបាលកម្ពុជាមិនអាចបំភ្លេចបាន គឺការចូលរួមជាមួយពិភពលោកក្នុងការអនុវត្ត យុទ្ធសាស្ត្រសូន្យបី ដែលបានសំរេចដោយអង្គការសហប្រជាជាតិដើម្បីលុបបំបាត់ទាំងស្រុងនូវការចម្លងមេរោគអេដស៍នាឆ្នាំ២០២០។

៨. ផ្អែកតាមបទពិសោធន៍គ្រប់គ្រងនិងដឹកនាំ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមទាំងសម្រេចបានលទ្ធផលជាផ្លែផ្កាជាច្រើន ក្នុងការគ្រប់គ្រងវិស័យវិស័យព័ត៌មាន និង សកម្មភាពកំចាត់មីន និង ចូលរួមគ្រប់គ្រងនិងដឹកនាំការស្តារនិងអភិវឌ្ឍវិស័យកសិកម្មជូនប្រទេសជាតិ ខ្ញុំជឿជាក់ថា ក្រោយពីបានប្រកាសជាផ្លូវការ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង ម៉ូលី** ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ឯកឧត្តមទេសរដ្ឋមន្ត្រី រួមជាមួយថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍នឹងគ្រប់គ្រងនិងដឹកនាំសកម្មភាពប្រយុទ្ធនឹងជម្ងឺអេដស៍ ឱ្យមានសន្ទុះរីកចម្រើនខ្លាំងក្លាថែមទៀតក្នុងការអនុវត្តកម្មវិធីនយោបាយ **យុទ្ធសាស្ត្រចតុកោណ -ដំណាក់កាលទី៣** របស់សម្តេចតេជោនាយករដ្ឋមន្ត្រី សម្រាប់នីតិកាលទី៥នេះ ។

៩. ជាទីបញ្ចប់ ជាថ្មីម្តងទៀត ក្នុងនាមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមប្រសិទ្ធិពរជ័យជូនឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង ម៉ូលី** ក្នុងឋានៈជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សូមឯកឧត្តមទទួលបានជោគជ័យក្នុងភារកិច្ចបំរើជាតិមាតុភូមិជាភិយ្យោភាព ។ ជាមួយនេះ ខ្ញុំសូមប្រសិទ្ធិពរជ័យជូនឯកឧត្តម **នុត សុខុម** ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ថ្នាក់ដឹកនាំ និង មន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរអេដស៍ បានប្រកបដោយសិរីមង្គល វិបុលសុខ សុភមង្គលជានិច្ចនិរន្តន៍ ។

***សូមអរគុណ !***